01642893

D363/1.1.3

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 06 / 01 / 2020
ម៉ោង (Time/Heure): 15 : 39
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅនឹងសំណើរបស់ អោ អាន**
**ទាក់ទងនឹងការទទួលសំណុំរឿង០០៤/២**

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Brenda J. HOLLIS

សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Martin KAROPKIN
ចៅក្រម យូរ ឧត្តរា

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់
នៃសំណុំរឿង ០០៤/២

សហមេធាវី អោ អាន:
លោក មុំ លុយ
លោក Richard ROGERS
លោក Göran SLUITER

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមធ្វើការឆ្លើយតបទៅនឹងលិខិតរបស់សហមេធាវី អោ អាន ("អោ អាន") ដែលបានបញ្ជូនតាមរយៈសារអេឡិចត្រូនិកជូនដល់ចៅក្រមទាំងប្រាំរូបរបស់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដោយស្នើឲ្យ អ.ជ.ស.ដ បញ្ជាក់អះអាងថា សំណុំរឿង០០៤/២ មិនត្រូវបានទទួលបណ្តឹងដោយស្របច្បាប់ទៅខ្លួននោះទេ ឬតាមរបៀបផ្សេងពីនេះ សូមឲ្យ អ.ជ.ស.ដ ផ្តល់សេចក្តីណែនាំអំពីការដាក់អញ្ញត្រកម្ម និងការអនុញ្ញាតឲ្យ អោ អាន មានពេលវេលាគ្រប់គ្រាន់ (យ៉ាងហោចណាស់ ៦០ថ្ងៃ) ដើម្បីដាក់អញ្ញត្រកម្មរបស់គាត់ ("សំណើរបស់ អោ អាន")[1]។ ដូចបានរៀបរាប់យ៉ាងលម្អិតខាងក្រោម អោ អាន i) បានយល់ច្រឡំចំពោះមូលដ្ឋានច្បាប់ក្នុងការដែល អ.ជ.ស.ដ ត្រូវបានទទួលយកសំណុំរឿងនេះ; ii) តវ៉ាទាំងខុសថា សិទ្ធិរបស់ អោ អាន ត្រូវបានរំលោភ និង iii) មិនបានអនុវត្តតាមសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត")[2]។

2. អាស្រ័យហេតុនេះ ស.ព.អ សូមស្នើឲ្យ អ.ជ.ស.ដ i) បដិសេធសំណើរបស់ អោ អាន តាមរយៈការបញ្ជាក់អះអាងថា ខ្លួនពិតជាបានទទួលយកសំណុំរឿង០០៤/២ មែន ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[3] ដោយយកសំណុំរឿងនេះទៅជំនុំជម្រះ; ii) អនុញ្ញាតតាមសំណើរបស់ អោ អាន ដែលសុំពេលវេលាគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំអញ្ញត្រកម្មស្របច្បាប់របស់គាត់ និង iii) បញ្ចូលលិខិតរបស់ អោ អាន ទៅក្នុងសំណុំរឿង និងបង្គាប់ឲ្យ អោ អាន អនុវត្តតាមសេចក្តីណែនាំអនុវត្តគ្រប់សំណើសុំនាពេលអនាគតទាំងអស់។

## II. ប្រវត្តិនីតិវិធី

[1] *សូមមើល* សារអេឡិចត្រូនិកដែលបានផ្ញើជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពី Göran Sluiter នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ នៅវេលាម៉ោង ៣:៣៣ រសៀល។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីផ្សេងទៀតត្រូវបានចម្លងជូនផងដែរ ចំណែកភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានចម្លងជូនឡើយ។ ភ្ជាប់ទៅនឹងសារអេឡិចត្រូនិកនេះ គឺលិខិតមួយច្បាប់ពីសហមេធាវីការពារក្តីជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ("សំណើរបស់ អោ អាន")។

[2] អនុវត្តតាមសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅ អ.វ.ត.ក (វិសោធនកម្មលើកទី ៨) ដែលបានកែប្រែនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ("សេចក្តីណែនាំអនុវត្ត"), អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី ៨។

[3] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

3. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសន្និដ្ឋានផ្នែកច្បាប់ខុសៗគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប ("ស.ច.ស") ក្រោយពីបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនទៅលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹង អោ អាន[4]។

4. ខណៈដែល អ.ប.ជ បានពិចារណាជាឯកច្ឆន្ទថា វាជារឿងខុសច្បាប់សម្រាប់ ស.ច.ស. ដែលបានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា[5] អ.ប.ជ មិនអាចរកបានសម្លេងភាគច្រើនលើសលប់ដែលតម្រូវ ដើម្បីចេញសេចក្តីសម្រេចស្តីពីផលប៉ះពាល់នៃកំហុសនេះ អំពីស្ថានភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[6]។ ចៅក្រមបីរូបបានសម្រេចតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ និងមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ[7] ចំណែកចៅក្រមពីររូបផ្សេងទៀតបានសម្រេចទុកជាមោឃៈនូវដីកាសម្រេចលើកលែងចោទប្រកាន់ និងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[8]។ ចៅក្រមទាំងពីររូបដែលតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានថ្លែងថាដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានច្រានចោល និងនៅតែមានសុពលភាព អាស្រ័យហេតុនេះ តាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង សំណុំរឿងនេះត្រូវបានប្តឹងទៅ អ.ជ.ស.ដ ដោយផ្អែកតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ[9]។

## III. ច្បាប់ជាធរមាន

5. វិធាន ៧៧(១៣)(ខ) ចែងថា៖

---

[4] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ")។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ និងឲ្យបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចំណែកសហចៅក្រមស៊ើបអង្កេតជាតិ បានលើកលែងចោទប្រកាន់ប្រឆាំងនឹងគាត់។

[5] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ផ្នែកសម្រេចសេចក្តី KH 01634854-55។

[6] *សូមមើល* អង្គជំនុំជម្រះសាលាដំបូងក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន"), វិធាន ៧៧(១៣)។

[7] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១៧០-៣០២ ("យោបល់របស់ចៅក្រមជាតិ")។

[8] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ៣០៤-៦៩៤ ("យោបល់របស់ចៅក្រមអន្តរជាតិ"), ជាពិសេស កថាខណ្ឌ ៦៨២-៦៨៤។

[9] ឯកសារ **D359/24 & D360/33** យោបល់របស់ចៅក្រមអន្តរជាតិ, ផ្នែកសម្រេចសេចក្តី ត្រង់ KH 01635147។

សេចក្តីសម្រេចរបស់អង្គ[បុរេ]ជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមាន ពីចៅក្រម ៤(បួន)រូប យ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើន ដែលតម្រូវមិនអាចរកបានទេ *សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ* របស់អង្គ [បុរេ] ជំនុំជម្រះ *ត្រូវអនុវត្ត* ដូចខាងក្រោម៖ [...]។ ខ) ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ *ត្រូវសម្រេចប្តឹងទៅ* អង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត[10]។

6. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

7. វិធាន១(២) ចែងជាផ្នែកពាក់ព័ន្ធថា៖

ការយោងវិធានផ្ទៃក្នុងនេះ ចំពោះសហចៅក្រមស៊ើបអង្កេត រួមមាន សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការរួមគ្នា និងធ្វើតែម្នាក់ឯង។

8. សេចក្តីណែនាំអនុវត្តផ្នែកពាក់ព័ន្ធចែងថា៖

ការដាក់ឯកសារនៅ អ.វ.ត.ក និងការទំនាក់ទំនងទៅវិញទៅមកជាមួយបុគ្គលដែលមានសិទ្ធិដាក់ឯកសារ ត្រូវធ្វើដោយផ្ទាល់ជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ទៅតាមករណីសមស្រប (ដែលបន្ទាប់ពីនេះហៅកាត់ថា ក្រឡាបញ្ជីដែលពាក់ព័ន្ធ) តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង[11]។

## IV. សារណា

### ក. អង្គជំនុំជម្រះសាលាដំបូងគឺបានទទួលតាមផ្លូវច្បាប់នូវសំណុំរឿង០០៤/២ ដោយឈរលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

[10] សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*។

[11] សេចក្តីណែនាំអនុវត្ត មាត្រា ២.១។

9. អោ អាន យល់ខុសទៅនឹងមូលដ្ឋានច្បាប់ដែល អ.ជ.ស.ដ បានទទួលសំណុំរឿង០០៤/២។ គាត់បានផ្តោតដោយភាន់ច្រឡំទៅលើថាតើ ចៅក្រម អ.ប.ជ *ចំនួនប៉ុន្មាននាក់* ដែលបាន សន្និដ្ឋានថា បទប្បញ្ញត្តិដែលតម្រូវនៅក្នុងវិធាន៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង អាចអនុវត្តបាន[12] ខណៈដែលកត្តាកំណត់ គឺថា *មិនមានមតិភាគច្រើនលើសលប់បានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍*។ ផ្ទុយទៅនឹងការអះអាងរបស់ អោ អាន ដែលថា "គ្មានវិធាន ឬយន្តការតាមបទបញ្ញត្តិច្បាប់ណាមួយ ដើម្បីដោះស្រាយទៅលើស្ថានភាពគតិយុត្តនេះ"[13] វិធាន៧៧(១៣)(ខ) *តម្រូវថា* អ.ជ.ស.ដ ត្រូវបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាលណាមតិភាគច្រើនលើសលប់មិនត្រូវរកបានទេនោះ។ ដោយសង្ខេបទៅ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែ "មានសុពលភាព" ជាដដែល ហើយ អ.ជ.ស.ដ *ត្រូវបានទទួល* ផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។ ចៅក្រមដែលបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គ្រាន់តែបានធ្វើនូវអ្វីដែលពួកគាត់ត្រូវបានតម្រូវឲ្យធ្វើតែប៉ុណ្ណោះ គឺត្រូវអនុវត្តបទប្បញ្ញត្តិដែលបានកំណត់ក្នុងវិធាន៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ពីព្រោះ មិនមានមតិភាគច្រើនលើសលប់ ដែលបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។

---

[12] *សូមអាន ឧទា.* សំណើរបស់ អោ អាន ទំព័រទី២ កថាខណ្ឌទី១ ទាំងស្រុង ("ដែលមួយក្នុងចំណោមនោះជាដីកាដំណោះស្រាយលើកលែងការចោទប្រកាន់កលើ លោក អោ អាន និងទទួលបានការគាំទ្រពីចៅក្រមភាគច្រើន") ទំព័រទី១ កថាខណ្ឌទី៣ ("ដោយការអនុវត្តជាឯកតោភាគី ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កំពុងព្យាយាមអនុវត្តគេចចេញពីច្បាប់របស់ អ.វ.ត.ក និងសហការីជាតិរបស់ខ្លួន(ចៅក្រមជាតិ) ដើម្បីបន្តនីតិវិធីដោយខុសច្បាប់លើបណ្តឹងប្រឆាំងនឹង អោ អាន") ទំព័រទី២ កថាខណ្ឌទី២ ទាំងស្រុង ("ចៅក្រមភាគតិច(២រូប)នៃអង្គបុរេជំនុំជម្រះ មិនអាចមើលរំលងសេចក្តីសម្រេចដោយចៅក្រមភាគច្រើន(៣រូប)នៃអង្គបុរេជំនុំជម្រះ ដែលចៅក្រមភាគច្រើនបានធ្វើមោឃភាពលើ *ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ* និងរកឃើញថាតុលាការខ្វះយុត្តាធិការក្នុងការចោទប្រកាន់ទៅលើលោក អោ អាន នោះទេ។ ការបញ្ជូនសំណុំរឿងរបស់លោក អោ អាន ទៅជំនុំជម្រះក្នុងខណៈដែលចៅក្រមភាគច្រើនរកឃើញថាតុលាការនេះខ្វះយុត្តាធិការ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ លោក អោ អាន ក្នុងការទទួលបានការសន្មត់ជាមុនថាគ្មានទោស។ ការសម្រេចបែបនេះមិនអាចធ្វើឡើង ដោយចៅក្រមអន្តរជាតិតែពីរ(២)រូបតែឯកឯងនោះទេ") ទំព័រទី២ កថាខណ្ឌទី១ ទាំងស្រុង ("ចៅក្រមអន្តរជាតិទាំងពីរ មិនអើពើទាំងស្រុងទៅលើការពិតដែលថាអង្គបុរេជំនុំជម្រះពុំទទួលបានសម្លេងភាគច្រើនក្នុងការច្រានចោល *ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ* ឬក៏ *ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់* ឬ បញ្ជាក់អំពីយុត្តាធិការបុគ្គលនោះទេ ហើយ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបែរជាទៅបង្គាប់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងលេខ ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយជឿជាក់ថាពួកគាត់មានអំណាចក្នុងការធ្វើដូច្នេះបាន ដោយអនុលោមតាមវិធាន៧៧(១៣)(ខ) នៃវិធាន ផ្ទៃក្នុង")។

[13] សំណើរបស់ អោ អាន ទំព័រទី២។

10. សំខាន់ក្នុងការកត់សម្គាល់ថា ទោះបីជាចៅក្រម អ.ប.ជ ខ្វែងយោបល់គ្នាលើផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយខ្វែងគ្នាក៏ដោយ ក៏ពួកគេបានយល់ស្របជាឯកច្ឆ័ន្ទលើគោលការណ៍ដែលថា ក្នុងពេលអវត្តមានសេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលប់ គោលជំហរបច្ចុប្បន្នដែលថា "ការស៊ើបអង្កេតត្រូវតែបន្ត" គឺជា "មុខងារសំខាន់មាននៅក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក"[14] និងជា "មូលដ្ឋាន និងកត្តាកំណត់"[15]។ គោលជំហរបច្ចុប្បន្ននេះមានចែងយ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក[16]។ ជាពិសេស ពួកគេបានសង្កត់ធ្ងន់ថា គោលជំហរបច្ចុប្បន្នជាមូលដ្ឋាននេះ "មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាននៃផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនេះក្លាយទៅជាគ្មានន័យនោះទេ"[17]។

11. ហេតុដូច្នេះ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺជាមូលដ្ឋាន និងកត្តាកំណត់នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ដែលផ្នែកសម្រេចសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ អ.ប.ជ លើដីកាដំណោះស្រាយ បានខកខានមិនបានទទួលសំឡេងភាគច្រើនលើសលប់ ដែលតម្រូវឲ្យមានចាំបាច់ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") គាំទ្រលទ្ធផលនេះ ដោយបានសម្រេចថាៈ

> ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះ មិន

[14] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១០៦។

[15] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១១២។

[16] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៥(៤), ៦(៤), ៧(៤)។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានធ្វើវិសោធនកម្មថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២០ថ្មី, ២៣ថ្មី។

[17] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១១២។

អាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[18]។

12. ដើម្បីឲ្យច្បាស់ អ.ជ.ត.ក បានពិភាក្សាសេណារីយ៉ូនេះក្នុងបរិបទដែល ស.ច.ស ណាម្នាក់ ឬទាំងពីរនាក់ បញ្ជូនការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ដែលបានស្នើឡើងទៅ អ.ប.ជ តាមរយៈយន្តការដោះស្រាយការខ្វែងយោបល់ ដែលបានប្រមើលទុកជាមុនដោយវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណា លទ្ធផលជាសារធាតុរបស់ អ.ជ.ត.ក គឺអាចអនុវត្តបានស្មើគ្នាចំពោះស្ថានភាពបច្ចុប្បន្ន ដែល អ.ប.ជ មិនបានទទួលសំឡេងភាគច្រើនលើសលប់ លើបញ្ហាថាតើ ចៅក្រមណាម្នាក់បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនខុស[19]។ សម្រេចផ្សេងពីនេះនឹងធ្វើដូចអ្វីដែលចៅក្រម អ.ប.ជ បានព្រមានជាឯកច្ឆ័ន្ទ - គឺទាត់ចោល ឬដកហូតគោលជំហរបច្ចុប្បន្នក្នុងវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងនូវឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា[20] ដែលនឹងនាំឲ្យមាន "លទ្ធផលផ្លូវច្បាប់ ដែលមិនសមហេតុផលទាល់តែសោះ"[21]។ និយាយម្យ៉ាងទៀត គោលជំហរដែលបានគាំទ្រដោយ អោ អាន នឹងធ្វើឲ្យក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ទៅជាមោឃៈ។

13. វិធាន ៧៩(១) ក៏បានកំណត់ផងដែរថា អ.ជ.ស.ដ *ទទួល*ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការគូសបញ្ជាក់របស់ អោ អាន ដែលថា [ទាំងមូល ឬ សំឡេងភាគច្រើនលើសលប់] របស់ អ.ជ.ស.ដ មិនបានទទួលសំណុំរឿងនេះ[22] គឺមិនពាក់ព័ន្ធឡើយ ដោយហេតុថា ការប្រើប្រាស់របស់វិធាន ៧៩(១) នៃពាក្យ "ឬ" ក៏អនុញ្ញាតឲ្យមានការប្ដឹងឲ្យទទួលយកនេះ ផ្អែកតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះពី ស.ច.ស ផងដែរ។ នៅពេលអានភ្ជាប់គ្នាជាមួយវិធាន ១(២) នៃវិធានផ្ទៃក្នុង ការ

---

[18] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា *ឌុច*") កថាខណ្ឌ ៦៥ *យោង* ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ វិធានផ្ទៃ ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[19] *ផ្ទុយទៅនឹង* សំណើរបស់ អោ អាន ទំព័រ ២ កថាខណ្ឌពេញទី១ ("ទោះយ៉ាងណាក្ដី ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះផ្អែកលើវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺមិនត្រឹមត្រូវទេ ដោយសារវិធាននេះគឺពិចារណាទៅលើតែស្ថានភាពដែលមានដីកាដំណោះស្រាយមួយតែប៉ុណ្ណោះ") (គូសបញ្ជាក់បន្ថែម)។

[20] *សូមមើល*កថាខណ្ឌ ១០ *យោងខាងលើ*។

[21] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១១២។

[22] សំណើរបស់ អោ អាន ទំព័រ ២ កថាខណ្ឌពេញទី១ ("វាគួរតែមានការលើកឡើងផងដែរនូវវិធាន ៧៩(១) ស្ដីពីការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងដោយអង្គបុរេជំនុំជម្រះ។ ជាថ្មីម្ដងទៀត អង្គបុរេជំនុំជម្រះ*ពុំ* បានប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូងនោះទេ") (គូសបញ្ជាក់ក្នុងច្បាប់ដើម)។

សំដៅណាមួយទៅលើ ស.ច.ស នៅក្នុងវិធានផ្ទៃក្នុង រួមបញ្ចូលទាំង ស.ច.ស ម្នាក់បំពេញកិច្ច ម្នាក់ឯង។ ដូច្នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនត្រូវបានបដិសេធដោយ សំឡេងលើសលប់ នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ នៅតែ "មានសុពលភាព" ហើយ អ.ជ.ស.ដ បានទទួលយ៉ាង ត្រឹមត្រូវដោយដីកានោះ។

14. បទប្បញ្ញត្តិជាកាតព្វកិច្ចនៃវិធានទាំងនេះត្រូវបានគាំទ្របន្ថែមទៀតដោយគោលបំណងនៃ កិច្ចព្រមព្រៀង របស់ អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក គឺដើម្បី "*កាត់សេចក្ដី*មេដឹកនាំជាន់ខ្ពស់កម្ពុជា ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម"[23]។ ពួកវាក៏ ស្របទៅនឹងគោលបំណងនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នាផងដែរ គឺដើម្បី "រារាំងការ ជាប់គាំងដែលធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ"[24]។

15. អ.ជ.ស.ដ មានបញ្ហាដែលមានយុត្តិកម្មនៅចំពោះមុខខ្លួន៖ ដើម្បីសម្រេចពីផលវិបាកផ្លូវច្បាប់នៃ ការបរាជ័យក្នុងការទទួលបានសំឡេងលើសលប់ភាគច្រើនរបស់ អ.ប.ជ ដើម្បីបដិសេធដីកាបញ្ជូន រឿងទៅជំនុំជម្រះ និងលទ្ធភាពអនុវត្តបាននៃបទប្បញ្ញត្តិជាកាតព្វកិច្ចរបស់វិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង ក្នុងស្ថានភាពបែបនេះ។ អាស្រ័យហេតុដូច្នេះ ផ្ទុយទៅនឹងការលើក ឡើងរបស់ អោ អាន ស.ព.អ សូមស្នើដោយគោរពថា វាមិនមែនជាវិធានការត្រឹមត្រូវឡើយដោយ គ្រាន់តែ "បដិសេធមិនធ្វើសកម្មភាពលើសំណុំរឿងនេះតែម្ដង" នោះ[25]។ ស.ព.អ សូមស្នើដោយ គោរពបន្ថែមទៀតថា "បដិសេធមិនធ្វើសកម្មភាពលើសំណុំរឿងនេះតែម្ដង" នឹងរំលោភលើវិធាន ក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក[26] គោលការណ៍សីលធម៌តុលាការ[27] ផលប្រយោជន៍យុត្តិធម៌ និងធ្វើឲ្យគ្រោះថ្នាក់ដល់កេរ្តិ៍ដំណែលរបស់តុលាការស្ដីពីកិច្ចដំណើរការនីតិវិធីដ៏មានតម្លាភាព។

---

[23] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ (គូសបញ្ជាក់បន្ថែម) ច្បាប់ អ.វ.ត.ក មាត្រា ១ (គូសបញ្ជាក់បន្ថែម)។

[24] *សូមមើល* ឯកសារ **D359/24 & D360/33** មតិយោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២៣ និង យោងសំអាង ខាងក្នុងនោះ។

[25] សំណើរបស់ អោ អាន ទំព័រ ២ កថាខណ្ឌពេញទី២ ("អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធមិនធ្វើសកម្មភាពលើសំណុំរឿង នេះតែម្ដង។ និយាយដូច្នេះមានន័យថា អង្គជំនុំជម្រះក៏អាចមិនអើពើនឹងលិខិតមួយនេះដែរ")។

[26] ដូចដែលបានពិភាក្សាក្នុងកថាខណ្ឌ ១៤ *យោងខាងលើ*។

[27] *សូមមើល ឧទា.* ក្រមសីលធម៌ចៅក្រម ដែលបានអនុម័តនៅសម័យប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងបានធ្វើវិសោធនកម្មកាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា៥។ សេចក្ដីថ្លែងនៅទីក្រុង ប៉េកាំងស្ដីពីគោលការណ៍នៃឯករាជភាពរបស់តុលាការនៅតំបន់ Lawasia, សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក, ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩៧, មាត្រា៣ ("ឯករាជភាពរបស់តុលាការតម្រូវថា៖ ក) តុលាការត្រូវសម្រេចលើបញ្ហានានាដែលនៅ

## ខ. សិទ្ធិរបស់ អោ អាន មិនត្រូវបានរំលោភបំពានឡើយ

16. អោ អាន ភ្ជាប់ការបរាជ័យក្នុងការទទួលបានសំឡេងភាគច្រើនលើសលប់ទៅនឹងសច្ចធារណ៍នៃនិរទោស និងគោលការណ៍*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងភាពច្បាស់លាស់នៃច្បាប់[28] ដោយបានអះអាងមិនត្រឹមត្រូវថា សំណុំរឿងប្រឆាំងនឹងរូបគាត់ត្រូវតែច្រានចោលអនុលោមតាមគោលការណ៍ទាំងអស់នោះ។ អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា "ការកំណត់ខុស [របស់ អោ អាន] ទៅលើវិធានបោះឆ្នោតមតិភាគច្រើនលើសលប់របស់អង្គជំនុំជម្រះនេះ ថាជា "ការបំពានសច្ចធារណ៍នៃនិរទោស" នោះ គឺជាការអនុវត្តគោលការណ៍នោះខុស និងយល់ខុសលើក្របខណ្ឌច្បាប់ អ.វ.ត.ក"[29]។ អោ អាន មិនត្រូវបានបញ្ជូនទៅជំនុំជម្រះដោយចៅក្រមពីររូបដូចដែលគាត់បានលើកឡើងនេះមែន[30]។ អោ អាន កំពុងត្រូវបានបញ្ជូនទៅជំនុំជម្រះផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពផ្លូវច្បាប់ ដែលមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលប់នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ ដូចដែលបានចែងយ៉ាងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង។

17. ដើម្បីឲ្យកាន់តែច្បាស់ សច្ចធារណ៍នៃនិរទោសធានាថា មុនពេលដែលទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានត្រូវបានកំណត់ ខាងអយ្យការត្រូវតែបង្ហាញភ័ស្តុតាងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឲ្យហួសពី

---

ចំពោះមុខខ្លួន ដោយយោងទៅតាមការវាយតម្លៃអនាគតិនៃអង្គហេតុ និងការយល់ដឹងរបស់ខ្លួនពីច្បាប់ ដោយមិនមានឥទ្ធិពលមិនត្រឹមត្រូវ ដោយចំពោះឬមិនចំពោះ ដោយមកពីប្រភពណាក៏ដោយ និង ខ) តុលាការមានយុត្តាធិការ ដោយផ្ទាល់ ឬដោយមធ្យោបាយពិនិត្យឡើងវិញ *លើគ្រប់បញ្ហាទាំងអស់ដែលមានចរិកស្របច្បាប់*") (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។ គោលការណ៍មូលដ្ឋាននៃឯករាជភាពរបស់តុលាការ ដែលបានអនុម័តដោយសេចក្ដីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ លេខ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និង លេខ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ គោលការណ៍ទី២ ("តុលាការត្រូវសម្រេចលើបញ្ហានានាដែលនៅចំពោះមុខខ្លួនដោយមិនលំអៀង នៅលើមូលដ្ឋាននៃអង្គហេតុនានា ហើយដោយយោងទៅតាមច្បាប់ ដោយមិនមានការកម្រិត ឥទ្ធិពលមិនត្រឹមត្រូវ ការជំរុញបញ្ចុះបញ្ចូល ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការជ្រៀតជ្រែក ដោយផ្ទាល់ ឬដោយប្រយោល ពីជ្រុងណាមួយ ឬ ដោយមូលហេតុណាមួយ")។ គោលការណ៍ទី៦ ("គោលការណ៍នៃឯករាជភាពរបស់តុលាការ មានសិទ្ធិអំណាច និងតម្រូវឲ្យតុលាការធានាថា កិច្ចដំណើរការនីតិវិធីត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ហើយថា សិទ្ធិរបស់ភាគីនានាត្រូវបានគោរព")។

[28] សំណើរបស់ អោ អាន ទំព័រ២។

[29] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៦៣។

[30] សំណើរបស់ អោ អាន ទំព័រ២។

វិមតិសង្ស័យ*នៅពេលជំនុំជម្រះ*[31]។ ជនសង្ស័យ ជនត្រូវចោទ និង ជនជាប់ចោទគ្រប់រូប រួមទាំង អោ អាន ផង ទទួលបានសច្ចធារណ៍នៃនិរទោសនេះ *លុះត្រាតែ និង រហូតទាល់តែ* ពួកគេត្រូវបានផ្តន្ទាទោសដោយសំឡេងភាគច្រើនលើសលប់របស់ចៅក្រម អ.ជ.ស.ដ។ អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទ និងយ៉ាងត្រូវត្រូវថា សច្ចធារណ៍នៃនិរទោសរបស់ អោ អាន ត្រូវបាន "ការពារគ្រប់គ្រាន់" ដោយបានគូសបញ្ជាក់ថា "នីតិវិធីនេះស្ថិតក្នុងដំណាក់កាលមុនជំនុំជម្រះ ដែលមិនពាក់ព័ន្ធនឹងការកំណត់ថា មានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ"[32]។

18. ស្រដៀងគ្នានេះ គោលការណ៍*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាវិបាកនៃសច្ចធារណ៍នៃនិរទោស និងជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែបង្ហាញនៅពេលជំនុំជម្រះឲ្យហួសពីវិមតិសង្ស័យ[33] មិនមែនតាមរយៈបទដ្ឋានភវនីយភាពជាធរមាននៅដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីឡើយ។ មុខងារចំបងរបស់វា គឺត្រូវដោះស្រាយបញ្ហាអង្គហេតុ និងចាប់ផ្តើមការរកឃើញជាក់ស្តែង នៅពេលមន្ទិលផ្នែកអង្គហេតុមិនត្រូវបាន

---

[31] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៣។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥ថ្មី។ *រដ្ឋអាជ្ញា ទល់នឹង Kayishema & Ruzindana*, ICTR-95-1-A, សាលដីកា (សំអាងហេតុ) អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១០៧។

[32] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៦៣។

[33] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ អ.ជ.ត.ក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន") កថាខណ្ឌ ៣១។ *រដ្ឋអាជ្ញា ទល់នឹង Limaj និងគូកន* IT-03-66-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពេញចិត្តដែលថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលជាបទជ្រែកចូលទៅក្នុងសច្ចធារណ៍នៃនិរទោស ហើយបន្ទុកបង្ហាញភស្តុតាងហួសពីវិមតិសង្ស័យ អនុវត្តចំពោះការរកឃើញនានាដែលបានតម្រូវឲ្យមានការកាត់ទោស បែបដូចជាពួកដែលបានប្រឌិតធាតុផ្សំនានានៃបទឧក្រិដ្ឋដែលបានចោទប្រកាន់។ [...] គោលការណ៍នេះគឺត្រូវជាពិសេសចំពោះទិដ្ឋភាពមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែបានរកឃើញឲ្យហួសពីវិមតិសង្ស័យ")។ *Renzaho ទល់នឹង រដ្ឋអាជ្ញា* ICTR-97-31-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំលឹកឡើងវិញថា ជាបទជ្រែកចូលទៅក្នុងសច្ចធារណ៍នៃនិរទោស ហើយបន្ទុកបង្ហាញភស្តុតាងហួសពីវិមតិសង្ស័យ គោលការណ៍*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តចំពោះការកឃើញនានាដែលតម្រូវឲ្យមានការកាត់ទោស បែបដូចជាពួកដែលបានប្រឌិតធាតុផ្សំនានានៃបទឧក្រិដ្ឋដែលបានចោទប្រកាន់") ។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន* IT-96-21-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦០១ ("ការកាត់ទោសត្រូវបានជាប់កាតព្វកិច្ចនៅក្នុងច្បាប់ដើម្បីបង្ហាញថា សំណុំរឿងដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទហួសពីវិមតិសង្ស័យ។ នៅពេលបិទបញ្ចប់សំណុំរឿង ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាននូវផលប្រយោជន៍នៃការសង្ស័យ ដូចដែលថាតើបទល្មើសត្រូវបានបង្ហាញសក្តិកម្មដែរ ឬយ៉ាងណា")។

លុបបំបាត់ដោយភ័ស្តុតាងដែលផ្តល់ជូននៅពេលជំនុំជម្រះ[34]។ និយាយម្យ៉ាងទៀត ជាចំបងវាគឺជាគោលការណ៍ដែលពាក់ព័ន្ធទៅនឹងការបញ្ជាក់អង្គហេតុ និងមិនមែនជាការបកស្រាយច្បាប់នោះទេ។ ទោះបីជានៅក្នុងករណីដ៏កម្រដែលវាអនុវត្តចំពោះបញ្ហាច្បាប់ ក្នុងនាមជាគោលការណ៍ពាក់ព័ន្ធទៅនឹងសច្ចធារណ៍នៃនិរទោស *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ពាក់ព័ន្ធជាចំបងទៅនឹងមន្ទិលសង្ស័យអំពីច្បាប់ព្រហ្មទណ្ឌជាសារធាតុ ឬការសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ[35]។ សំណួរដែលជាបញ្ហានៅ *ទីនេះ* គឺមិនមែនថាតើ អោ អាន មិនមានពិរុទ្ធភាព ឬមានពិរុទ្ធភាពតាមរយៈឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះទេ ប៉ុន្តែថាតើរូបគាត់នឹងត្រូវបានជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងនោះឬយ៉ាងណា។ ដូច្នេះ គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនត្រូវអនុវត្តទេ។

19. ជាចុងក្រោយ មិនមាន *ចន្លោះប្រហោងច្បាប់* ឬ ភាពមិនច្បាស់លាស់នៅទីនេះទេ បើទោះជាមានអំណះអំណាងរបស់ អោ អាន ក៏ដោយ[36]។ ដូចដែលបានពិភាក្សានៅក្នុង ផ្នែក IV.ក

---

[34] សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន, កថាខណ្ឌ ៣១។ សំណុំរឿង ០០៣-ឯកសារ **D87/2/1.7/1/1/7** [កោសលុប] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ [កោសលុប] លើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ, អ.ប.ជ, ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧, កថាខណ្ឌ ៦៥ (“អង្គបុរេជំនុំជម្រះពិចារណាថា ពុំចាំបាច់ពិនិត្យបន្ថែមទៀតទៅលើអំណះអំណាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ទេ ដោយសារគោលការណ៍នេះជាវិធាននៃភ័ស្តុតាង និងពុំមែនជាការបកស្រាយច្បាប់ទេ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ និងអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់រួចមកហើយ”។ *រដ្ឋអាជ្ញា ទល់នឹង Stakić*, IT-97-24-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ ៤១៦ (គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* “គឺអនុវត្តបានចំពោះការរកឃើញខាងផ្នែកអង្គហេតុ មិនមែនអង្គច្បាប់ទេ”)។

[35] *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Laurent Gbagbo និង Charles Blé Goudé*, ICC-02/11-01/15-744, សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Laurent Gbagbo និងលោក Charles Blé Goudé ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I នៃថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ដែលមានចំណងជើងថា “សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដើម្បីបង្ហាញសក្ខីកម្មដែលបានកត់ត្រាពីមុនស្របតាមវិធាន ៦៨(២)(ខ) និង ៦៨(៣)” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៣ (“អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សម្គាល់ថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺត្រូវបានបង្ហាញជាសង្ខេបនៅក្នុងមាត្រា ២២(២) នៃលក្ខន្តិកៈ ថាជាគោលគារណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវអនុវត្ត នៅពេលដែលភាពមិនច្បាស់លាស់កើតមាន នៅក្នុងការបកស្រាយនិយមន័យនៃឧក្រិដ្ឋកម្ម។”)។

[36] ខណៈដែល ចៅក្រម អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា “ដោយចេញដីកាដំណោះស្រាយដាច់ពីគ្នា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ប្រាសចាកពីតួនាទីរបស់ពួកគេ និងបង្កើតជាស្ថានភាពគតិយត្តិដែល

*យោងខាងលើ* វិធាន ៧៧(១៣)(ខ), ៧៩(១) និង ១(២) នៃវិធានផ្ទៃក្នុង កំណត់ថា ក្នុងករណីដែលមិនមានសំឡេងភាគច្រើនបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ គោលជំហរជាក់ស្តែងគឺថាត្រូវប្តឹងទៅ អ.ជ.ស.ដ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស ដែលបំពេញកិច្ចរួមគ្នា ឬ ស.ច.ស ណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ។ ដូចដែលបានអះអាងខាងលើ ការណ៍នេះឆ្លុះបញ្ចាំងគោលបំណងច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក នៅពេលដែលមិនមានសំឡេងភាគច្រើនលើសលប់នៅក្នុង អ.ប.ជ នោះ ការស៊ើបអង្កេត *ត្រូវ*បន្ត[37]។

## គ. សំណើរបស់ អោ អាន មិនបានអនុវត្តតាមសេចក្តីណែនាំអនុវត្ត

20. សេចក្តីសម្រេចរបស់ អោ អាន ក្នុងការបញ្ជូនសំណើរបស់គាត់តាមរយៈសារអេឡិចត្រូនិក ជាជាងការដាក់ជាផ្លូវការតាមរយៈអង្គភាពគ្រប់គ្រងតុលាការ គឺជាការមិនអនុវត្តតាមសេចក្តីណែនាំអនុវត្ត[38]។ ជាលទ្ធផល សំណុំរឿងនេះ គឺគ្មានតម្លាភាព និងមិនពេញលេញ ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលជាភាគីផ្លូវការមួយនៃសំណុំរឿង០០៤/២ មកដល់ពេលនេះក៏ត្រូវច្រានចោលមិនឲ្យដឹងអំពីខ្លឹមសារនៃសំណើសុំនេះដែរ ហេតុដូច្នេះ ទង្វើនេះក៏បានបដិសេធចំពោះឱកាសដើម្បីឆ្លើយតបទៅនឹងសំណុំនេះ។ អាស្រ័យហេតុនេះ ស.ព.អ សូមស្នើឲ្យ អ.ជ.ស.ដ i) កែតម្រូវលើបញ្ហានេះ

---

មិនធ្លាប់មាន" អ.ប.ជ បានអនុវត្តសិទ្ធិអំណាចក្នុងការត្រួតពិនិត្យ ដើម្បីស្តារនីត្យានុកូលភាព និងផ្តល់ឧបាស្រ័យនៃកិច្ចរបស់ ស.ច.ស (*សូមមើល* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ៨៩)។ *ផ្ទុយទៅនឹង* សំណើរបស់ អោ អាន ទំព័រ ២ ("គ្មានវិធាន ឬយន្តការតាមបទប្បញ្ញត្តិច្បាប់ណាមួយ ដើម្បីដោះស្រាយទៅលើស្ថានភាពគតិយុត្តដែលមិនធ្លាប់មាននេះ")។ ចំពោះ "ភាពមិនច្បាស់លាស់" *សូមមើល* ឯកសារ **D359/14.1.1** *មើល* សារអេឡិចត្រូនិកពី Göran Sluiter ផ្ញើជូនប្រធានផ្នែកគាំពារការការពារក្តី នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ EN 01623714 (ក្នុងនោះមេធាវីការពារក្តីប្រមើលថានឹងមានការជំនុំជម្រះមួយ និងស្នើសុំមូលនិធិគ្រប់គ្រាន់ដើម្បីត្រៀមសម្រាប់វា៖ "រឿងក្តីរបស់ អោ អាន មានភាពខុសគ្នាខ្លាំង។ ដោយមានដីកាដំណោះស្រាយពីរផ្ទុយគ្នា រូបគាត់ត្រូវបានបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយមួយរួចទៅហើយ។ តាមរយៈគោលជំហរពីមុនរបស់ អ.ប.ជ ក្នុងរឿងក្តីរបស់យើង មានឱកាសច្រើនដែលថា សំឡេងភាគច្រើននឹងមិនអាចរកបាននៅក្នុងបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយនេះទេ។ ជាលទ្ធផល ដីកាដំណោះស្រាយទាំងពីរមានសុពលភាព។ នៅក្នុងអំឡុងពេលនៃសវនាការសប្តាហ៍មុន ស.ព.អ បានបញ្ជាក់យ៉ាងច្បាស់ថា គាត់នឹងបញ្ជូនរឿងក្តី អោ អាន ទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ"។ នេះមានន័យថា យើងស្ថិតនៅក្នុងគោលជំហរមួយដែលថា យើងចាំបាច់ត្រូវរៀបចំត្រៀមសម្រាប់ការជំនុំជម្រះ។")។

[37] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ១០ ខាងដើម។

[38] សេចក្តីណែនាំអនុវត្ត មាត្រា ២.១។

តាមរយៈការដាក់បញ្ចូលលិខិតរបស់ អោ អាន ទៅក្នុងសំណុំរឿង និងជូនដំណឹងដល់ភាគីទាំងអស់អំពីការដាក់បញ្ចូលនេះ និង ii) បង្គាប់ឱ្យ អោ អាន ដាក់សំណើសុំនាពេលអនាគតទាំងអស់ឱ្យស្របតាមសេចក្ដីណែនាំអនុវត្ត។

## V. សេចក្ដីសន្និដ្ឋាន

21. ដោយសារ អ.ប.ជ ខកខានមិនអាចរកសម្លេងភាគច្រើនលើសលប់បាន ដើម្បីច្រានចោលដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង អោ អាន នោះដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ស្របតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) ដោយអានរួមគ្នាជាមួយនឹងវិធាន ១(២)។

22. អាស្រ័យហេតុនេះ សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ ស.ព.អ សូមស្នើដោយគោរពឱ្យអង្គជំនុំជម្រះសាលាដំបូង ៖

i) បដិសេធសំណើរបស់ អោ អាន តាមរយៈការបញ្ជាក់អះអាងថា ខ្លួនពិតជាបានទទួលសំណុំរឿង០០៤/២មែន ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីដំណើរការជំនុំជម្រះ;

ii) អនុញ្ញាតតាមសំណើរបស់ អោ អាន ដែលសុំពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំអញ្ញត្រកម្មស្របច្បាប់របស់គាត់; និង

iii) បញ្ចូលលិខិតរបស់ អោ អាន ទៅក្នុងសំណុំរឿង និងបង្គាប់ឱ្យ អោ អាន អនុវត្តតាមសេចក្ដីណែនាំអនុវត្តគ្រប់សំណើសុំនាពេលអនាគតទាំងអស់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |